# កិច្ចប្រជុំលើកទី៨ នៃក្រុមប្រឹក្សាភិបាលកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា



នារសៀលថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ នៅទីស្តីការក្រសួងបរិស្ថានមានរៀបចំកិច្ចប្រជុំលើកទី៨ នៃក្រុមប្រឹក្សាភិបាលកម្មវិធី សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (Cambodia Climate Change Alliance) ក្រោមអធិបតីភាព ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាភិបាលកម្មវិធី ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលមកពីក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដៃគូអភិវឌ្ឍន៍ រួមមាន សហភាពអឺរ៉ុប ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែត កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី និងមន្ត្រីកម្មវិធី សរុបចំនួន ៣២នាក់។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យមើលលទ្ធផលដែលសម្រេចបានពីការអនុវត្តកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី១ ឆ្នាំ ២០១០-២០១៤ និងវឌ្ឍនភាពនៃការរៀបចំឯកសារសំណើកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី២ ឆ្នាំ ២០១៤-២០១៩ សម្រាប់ដាក់ជូនក្រុមប្រឹក្សាកម្មវិធីពិនិត្យ និងសម្រេច។

មានប្រសាសន៍ស្វាគមន៍ ឯកឧត្តមរដ្ឋមន្ត្រីបានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ក្រសួងបរិស្ថានក្នុងកិច្ចការពារគុណភាពបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការធានាបាននូវជីវភាពរស់នៅប្រកបដោយនិរន្តរភាព។ ឯកឧត្តមបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការរៀបចំគោលនយោបាយបរិស្ថាន ដោយផ្អែកជាពិសេសលើការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ដោយរួមទាំងការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ និងការរៀបចំកម្មវិធីអប់រំសម្រាប់បណ្តុះបណ្តាលអ្នកជំនាញផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុនៅកម្រិតសាកលវិទ្យាល័យ។

ឯកឧត្តម ក៏បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធិផលសំខាន់ៗ ដែលកម្មវិធីសម្រេចបានកន្លងមក ដូចជាការគាំទ្រដំណើរការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ការសិក្សា និងការរៀបចំសំណើដំបូងស្តីពីក្របខ័ណ្ឌច្បាប់ប្រែប្រួលអាកាសធាតុ និងក្របខ័ណ្ឌត្រួតពិនិត្យវាយតម្លៃការងារប្រែប្រួលអាកាស

ធាតុ ការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ការគាំទ្រកិច្ចចរចាស្តីពីការប្រែប្រួលអាកាសធាតុអន្តរជាតិក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ការអប់រំផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់មន្ត្រីមូលដ្ឋាននៅគ្រប់ខេត្តក្រុង។ល។

លោក **ទិន ពន្លក** អគ្គនាយករងនៃក្រសួងបរិស្ថាន បានបន្ថែមថា កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា បានផ្តល់ការគាំទ្រជាជំនួយឥតសំណងដល់គម្រោងចំនួន២០ លើគ្រប់វិស័យដែលទាក់ទងនឹងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (ក្នុងនោះ ១៤គម្រោងត្រូវបានអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា និង៦គម្រោងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល) ដែលគិតជាទឹកប្រាក់សរុបប្រមាណជាង ៦ លានដុល្លារសហរដ្ឋអាមេរិក។ គ្រួសារចំនួន**១៦.០០០** បានទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងបន្សាំសាកល្បង ពលរដ្ឋជាង **៣៥.០០០ នាក់** បានទទួលផលពីការបណ្តុះបណ្តាស្តីពីការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងប្រមាណ១៧%នៃគ្រួសារនៅក្នុងភូមិគោលដៅគម្រោង បានអនុវត្តតាមបច្ចេកទេសបន្សាំដែលបានបង្ហាញ។ គម្រោងជំនួយឥតសំណងទាំងនេះគ្របដណ្តប់លើជាង៥០ ស្រុកផ្សេងៗគ្នា។

អង្គប្រជុំក៏បានពិនិត្យពិភាក្សាលើសំណើកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី២ ដោយក្នុងនោះដៃគូអភិវឌ្ឍន៍ បានឯកភាពផ្តល់នូវជំនួយឥតសំណងបន្តចំនួនប្រមាណ ១២,៤ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០១៤-២០១៩ ដោយផ្តល់អាទិភាពលើ ៖

- **ការពង្រឹងអភិបាលកិច្ចហិរញ្ញវត្ថុអាកាសធាតុ ៖** ក្របខ័ណ្ឌស្ថាប័ន និងច្បាប់ក្របខ័ណ្ឌគណនេយ្យភាព/ការត្រួតពិនិត្យ និងវាយតម្លៃការគាំទ្រដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តសកម្មភាពសំខាន់ៗដែលមានចែងនៅក្នុងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ ដោយរួមបញ្ចូលទាំងជំនួយឥតសំណង។
- **ការទាក់ទាញយកមកប្រើប្រាស់នូវធនធានពីប្រភពក្នុង និងក្រៅស្រុក ពីប្រភពសាធារណៈ និងឯកជនក្នុងការគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា២០១៤-២០២៣ ៖** ការសម្របសម្រួលរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយការគាំទ្រផ្តល់ប្រឹក្សាលើបែបបទហិរញ្ញប្បទាន/ការកៀរគរធនធាន ការវិភាគចំណាយ-ការខាតបង់ការតាមដានពិនិត្យលើការចំណាយការប្រែប្រួលអាកាសធាតុកិច្ចពិភាក្សាជាមួយវិស័យឯកជន កិច្ចចរចាអន្តរជាតិ ការទទួលស្គាល់ជាផ្លូវការដោយមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង។
- **ការអភិវឌ្ឍធនធានមនុស្ស និងបច្ចេកវិទ្យា សម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ៖** ការផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងដែលមានភាពច្នៃប្រឌិតថ្មីៗ របស់អង្គការមិនមែនរដ្ឋាភិបាល/វិស័យឯកជនការបង្កើតភាពជាដៃគូជាមួយក្រសួងអប់រំ និងសាកលវិទ្យាល័យនានា លើការអប់រំការប្រែប្រួលអាកាសធាតុការបង្កើតនូវប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងយុទ្ធនាការបង្កើនចំណេះដឹង និងការបង្កើតជាស្តង់ដាសម្រាប់ចែករម្លែកការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។

អង្គប្រជុំក៏បានពិនិត្យផងដែរលើលទ្ធភាពនៃការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយ កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (Strategic Programme for Climate Resilience) ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការធ្វើផែនទីភាពងាយរងគ្រោះលម្អិត សហការជាមួយក្រសួងផែនការដើម្បីតាមដានសូចនាករប្រែប្រួលអាកាសធាតុដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ២០១៤-២០១៨ និងគាំទ្រដល់ការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ៕